# ការឆែកពិនិត្យសុខភាពកូនរបស់លោកអ្នក មុនចូលអាយុ២ឆ្នាំ

សូមបោះពុម្ពពាក្យវាយតម្លៃរបស់មាតាបិតា អំពីស្ថានភាពខាងការចំរើនលូតលាស់ (PEDS) មួយច្បាប់ដែលបកប្រែរួចចេញពីវ៉ិបសាយ www.mhcs.health.nsw.gov.au ហើយបំពេញ មុនពេលលោកអញ្ជើញទៅ ឬស្នើសុំគិលានុបដ្ឋាកមើលថែសុខភាពកុមារឲ្យជួយបំពេញជូនលោកអ្នក។

សូមឆ្លើយនឹងសំនួរទាំងនេះអំពីកូនរបស់លោកអ្នក មុនពេលលោកអ្នកអញ្ជើញទៅជួបគិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់លោកអ្នក។

| ការស្តាប់ឮ | បាទ/ចាស៎ | ទេ | មិនប្រាកដ |
|---|---|---|---|
| តើលោកអ្នកមានកង្វល់អំពីការស្តាប់ឮរបស់កូនលោកអ្នកឬ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកបង្ហាញឲ្យឃើញថាវាបានយល់ពាក្យថ្មីខ្លះ រៀងរាល់អាទិត្យឬទេ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកអាចធ្វើតាមពាក្យបង្គាប់បំបែកងាយៗឬទេ ឧទាហរណ៍ "យកបាល់"? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកចង្អុលទៅមនុស្ស ផ្នែករូបកាយ ឬប្រដាប់ក្មេងលេងឬទេនៅពេលសួរ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកចេះបន្តរៀនពាក្យថ្មីៗដើម្បីនិយាយឬទេ ទោះជាពាក្យនោះមិនសូវច្បាស់ក្តី? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកចេះស្តាប់រឿង ឬចម្រៀងងាយៗឬទេ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកចេះដាក់ផ្គុំពាក្យពីរ ឬច្រើនម៉ាត់រួមបញ្ចូលគ្នា នៅក្នុងឃ្លាខ្លីៗឬទេ ឧទាហរណ៍ "ទឹកផ្លែឈើថែមទៀត"? | ☐ | ☐ | ☐ |

| ការមើលឃើញ | | | |
|---|---|---|---|
| តើលោកអ្នកមានកង្វល់អំពីការមើលឃើញរបស់កូនលោកអ្នកឬ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកមានភ្នែកស្រលៀងឬទេ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកមានការលំបាកក្នុងការមើលឃើញវត្ថុតូចៗឬទេ? | ☐ | ☐ | ☐ |
| តើកូនរបស់លោកអ្នកសម្គាល់ដឹងមនុស្ស និងវត្ថុដែលធ្លាប់ស្គាល់បានពីចម្ងាយឬទេ? | ☐ | ☐ | ☐ |
| តើមាននរណាម្នាក់នៅក្នុងគ្រួសារមានបញ្ហាក្នុងការមើលឃើញឬទេ? | ☐ | ☐ | ☐ |

**ប្រសិនបើលោកអ្នកឆ្លើយថា បាទ/ចាស៎ ទៅនឹងសំនួរទាំងនេះណាមួយ សូមនិយាយប្រាប់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកមើលថែសុខភាពកុមារ និងគ្រួសាររបស់លោកអ្នក។**

**លទ្ធផល** ☐ ធម្មតា ☐ បញ្ជូន ☐ ពិនិត្យឡើងវិញ

# ប្រធានបទសំរាប់ការពិភាក្សានៅក្នុងអាយុ២ឆ្នាំ

- សុវត្ថិភាពក្មេង ការត្រួតពិនិត្យ និងចល័តភាពប្រែប្រួល
- របបចំណីអាហារគ្រួសារ
- គេង/ភ្ញាក់នៅពេលយប់
- មានចិត្តឆេវឆាវ
- មានបញ្ហាជាមួយបងប្អូន
- ជក់បារី
- ការហាត់រៀនមើលកូន ឧទាហរណ៍ ការប្រៀនប្រដៅ ការដាក់ព្រំដែន
- ការហ្វឹកហ្វឺនប្រើបង្គន់
- ការមើលថែធ្មេញ
- ការពារពន្លឺថ្ងៃ
- កន្លែងមើលថែក្មេង/ក្រុមកុមារតូចៗលេង
- ឥរិយាបទចេះល្បួងលោមខ្លួនឯង ឧទាហរណ៍ ជញ្ជក់មេដៃ ប្រដាប់ក្មេងលេងដែលចូលចិត្ត ក្បាលដោះជ័រ
- ការចាក់ថ្នាំបង្ការរោគ
- ការនិយាយស្ដី និងភាសា
- ជំនួយគ្រួសារ និងបញ្ហាដទៃទៀតណាមួយ